# ព័ត៌មានគម្រោង

## ការពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និង សហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា តាមរយៈទិន្នន័យបើកទូលាយ និងអក្ខរកម្មឌីជីថល

ការពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជា តាមរយៈទិន្នន័យបើកទូលាយ និងអក្ខរកម្មឌីជីថល គឺជាគម្រោងដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីមជ្ឈមណ្ឌលសម្រាប់សហគ្រាសឯកជនអន្តរជាតិ (CIPE)។

## ព័ត៌មានទូទៅ

វិស័យឯកជនអាចពង្រឹងការដឹកនាំតាមបែបប្រជាធិបតេយ្យ តាមរយៈការរាប់បញ្ចូលឱ្យបានទូលំទូលាយចំពោះក្រុមដែលមិនសូវទទួលបានឱកាសនៅក្នុងសង្គម។ គម្រោងនេះនឹងលើកកម្ពស់សិទ្ធិអំណាចសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាស្ត្រី និងជនជាតិដើមភាគតិច ព្រមទាំងការពង្រឹងសិទ្ធិឌីជីថល អក្ខរកម្មហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលគោលនយោបាយ ដើម្បីយល់ដឹងពីគោលនយោបាយគ្រប់គ្រងវិស័យឯកជននៅប្រទេសកម្ពុជា។ ការយល់ដឹងកាន់តែច្បាស់អំពីច្បាប់នេះនឹងជួយសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចាប់ផ្តើមអាជីវកម្មរបស់ពួកគេ។

គម្រោងនេះមានគោលដៅចំនួន៤ ដូចជា៖ បង្កើតការយល់ដឹងកាន់តែប្រសើរអំពីវិស័យឯកជននៅកម្ពុជា តាមរយៈទិដ្ឋភាពរបស់ស្ត្រី និងជនជាតិដើមភាគតិច, លើកកម្ពស់សិទ្ធិអំណាចស្ត្រី និងជនជាតិដើមភាគតិចក្នុងការធ្វើអាជីវកម្ម, បង្កើតបណ្តុំធនធានចំណេះដឹង ដែលជាមធ្យោបាយផ្តល់ការណែនាំដើម្បីចាប់ផ្តើមអាជីវកម្ម, និងចូលរួមចំណែកក្នុងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាជាមួយនឹងបរិយាបន្នសង្គម។

នៅពេលបញ្ចប់ គម្រោងនេះនឹងធ្វើបច្ចុប្បន្នភាព និងប្រមូលរៀបចំច្បាប់គ្រប់គ្រងវិស័យឯកជននៅកម្ពុជា។ គម្រោងនេះក៏នឹងបង្កើតកិច្ចសន្ទនាជាមួយនឹងសហគ្រិន ដើម្បីកំណត់ពីតម្រូវការក្នុងការពង្រីកអាជីវកម្មរបស់ពួកគេដែលផ្សារភ្ជាប់នឹងបទប្បញ្ញត្តិថ្មីៗនិងប្រព័ន្ធផ្សព្វផ្សាយឌីជីថល និងផលិតធនធានចំណេះដឹង ដែលសហគ្រិនអាចប្រើជាជំនួយដល់ការអនុលោមតាមបទប្បញ្ញត្តិថ្មីៗនៅក្នុងដំណើរការអាជីវកម្មរបស់ពួកគេ។

## គោលបំណង

ដើម្បីលើកកម្ពស់សិទ្ធិអំណាចដល់អាជីវកម្មក្នុងស្រុក និងសហគ្រិនដែលមិនសូវទទួលបានឱកាស ឱ្យបានចូលរួមក្នុងដំណើរការរៀបចំគោលនយោបាយសេដ្ឋកិច្ច

- ជួយសម្រួលដល់សហគ្រាសធុនតូច និងមធ្យម ក្នុងការចូលទៅស្វែងរកព័ត៌មាន និងសំណុំទិន្នន័យដែលពាក់ព័ន្ធ។
- រួមបញ្ចូលសហគ្រាសធុនតូច និងមធ្យម និងសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទៅក្នុងកិច្ចសន្ទនា និងការបណ្តុះបណ្តាលចំណេះដឹងផ្នែកច្បាប់ និងអក្ខរកម្មឌីជីថល។
- បង្កើតបណ្តុំធនធានចំណេះដឹង ដើម្បីផ្តល់ជាការណែនាំក្នុងការចាប់ផ្តើម/ពង្រឹងអាជីវកម្ម និងអនុសាសន៍កែលម្អបទប្បញ្ញត្តិដែលមានស្រាប់សម្រាប់វិស័យឯកជន ក្នុងន័យបង្កើតឱកាសប្រកបដោយបរិយាបន្ន។

## រយៈពេលអនុវត្តគម្រោង

ខែមីនា ឆ្នាំ២០២៣ ដល់ ខែមីនា ឆ្នាំ២០២៤



# អ្នកទទួលផល

ក. **ដោយផ្ទាល់៖** អ្នកចូលរួមសរុបចំនួន៤០០នាក់នៅគ្រប់កម្មវិធី (យ៉ាងហោចណាស់៥០នាក់ក្នុង១កម្មវិធី) ដែលមកពីសហគ្រាសធុនតូច និងមធ្យម និងសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលក្នុងមានចំនួនស្ត្រីយ៉ាងតិចពាក់កណ្តាលនៃអ្នកចូលរួមសរុប។

ខ. **ថ្នាលឌីជីថល៖** ធនធានចំណេះដឹងនៅលើទំព័រព័ត៌មានទិន្នន័យស្តីពីកញ្ចប់ព័ត៌មានសហគ្រាសធុនតូច និងមធ្យម និងផតខាសត៍ផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អង្គការអូឌីស៊ី។

គ. **ដោយប្រយោល៖** រដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន សាធារណជន រួមទាំងអ្នកស្រាវជ្រាវ។

# ទីតាំងសម្រាប់កិច្ចសន្ទនា និងការបណ្តុះបណ្តាល

គម្រោងនេះផ្តោតលើសហគ្រាសធុនតូច និងមធ្យម និងសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ នៅទូទាំងប្រទេស។ ដើម្បីបង្កលក្ខណៈងាយស្រួលនិងទូលំទូលាយដល់អ្នកចូលរួម កិច្ចសន្ទនានិងការបណ្តុះបណ្តាលនឹងរៀបចំឡើងនៅទីតាំងភូមិសាស្ត្រគន្លឹះចំនួន៥ ដូចជា៖ រាជធានីភ្នំពេញ ខេត្តសៀមរាប មណ្ឌលគិរី ព្រះវិហារ និងកំពត។



# សកម្មភាព

### ដំណាក់កាលទី១៖ ឈ្វេងយល់ផ្នែកច្បាប់គ្រប់គ្រងវិស័យឯកជននៅប្រទេសកម្ពុជា

- **ការស្រាវជ្រាវតាមឯកសារ៖** ប្រមូល និងវិភាគបទប្បញ្ញត្តិដែលមានស្រាប់ ដែលគ្រប់គ្រងវិស័យឯកជននៅកម្ពុជា។
- **កិច្ចសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ៖** បំពេញចន្លោះខ្វះខាតដែលនៅក្នុងការស្រាវជ្រាវតាមឯកសារ និងដើម្បីកំណត់ពីផលលំបាករបស់សហគ្រាសធុនតូច និងមធ្យម និងសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងការឈ្វេងយល់ និងអនុលោមទៅតាមបទប្បញ្ញត្តិដែលមានស្រាប់។

### ដំណាក់កាលទី២៖ ការពិគ្រោះយោបល់ និងការបណ្តុះបណ្តាល

- **កិច្ចសន្ទនា៖** ចងក្រងទិន្នន័យ តាមរយៈការប្រមូលធាតុចូលជុំវិញបញ្ហាប្រឈមរបស់សហគ្រាសធុនតូច និងមធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងវិស័យឯកជននៅកម្ពុជា, សន្តិសុខឌីជីថលនិងសុវត្ថិភាពឌីជីថល, និងឥទ្ធិពលពីបទប្បញ្ញត្តិ និងគោលនយោបាយមកលើអាជីវកម្មរបស់ពួកគេ។
- **ការបណ្តុះបណ្តាល៖** ផ្តល់ការបណ្តុះបណ្តាលផ្នែកអាជីវកម្ម និងសុវត្ថិភាព/សិទ្ធិឌីជីថល ដល់សហគ្រាសធុនតូច និងមធ្យម និងសមាជិកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

### ដំណាក់កាលទី៣៖ ការផលិតធនធានចំណេះដឹង

- **បញ្ជីសហគ្រាសធុនតូច និងមធ្យម៖** បង្កើតបញ្ជី និងទំព័រព័ត៌មានទិន្នន័យស្តីពីកញ្ចប់ព័ត៌មានសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ដែលអាចចូលទៅស្វែងរកបានជាសាធារណៈ
- **បទប្បញ្ញត្តិសង្ខេប៖** ផ្សព្វផ្សាយព័ត៌មានសង្ខេបពីវិស័យឯកជន ដូចជាដំណើរការចុះបញ្ជីរបស់ធុរកិច្ចថ្មី, ច្បាប់, និងការការពារទិន្នន័យ
- **ខ្លឹមសារឌីជីថល និងការផ្សព្វផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម៖** ផលិតផតខាសត៍ និងក្រាហ្វិកព័ត៌មានអំពីអក្ខរកម្មហិរញ្ញវត្ថុ និងច្បាប់ទាក់ទងពន្ធដារ។

# ព័ត៌មានទំនាក់ទំនង


**កញ្ញា Jennifer Anderson**

- នាយកគ្រប់គ្រងកម្មវិធីប្រចាំទ្វីបអាស៊ី | janderson@cipe.org
- មជ្ឈមណ្ឌលសម្រាប់សហគ្រាសឯកជនអន្តរជាតិ (CIPE)

**លោក ធី ទ្រី**

- នាយកប្រតិបត្តិ/និពន្ធនាយក | contact@opendevcam.net
- អង្គការទិន្នន័យអំពីការអភិវឌ្ឍ



CIPE CENTER FOR INTERNATIONAL PRIVATE ENTERPRISE

អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia Organization